ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.)

**ECONOMIC, SOCIAL AND CULTURAL COUNCIL (ECOSOCC)**



ព្រឹត្តិការណ៍អង្គរសង្ក្រាន្ត២០២៥



រោងចក្រដំឡើងគ្រឿងបង្គុំរថយន្ត Ford




ពិព័រណ៍សិល្បៈ កម្ពុជា កូរ៉េ

# របាយការណ៍វិភាគស្ថានភាព

# សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន

# ប្រចាំត្រីមាសទី១ ឆ្នាំ២០២៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
**ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**
លេខ: ..........២៩ របក..........ក.ស.វ.

ថ្ងៃសុក្រ ៨រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥

# របាយការណ៍
# ស្តីពី
# ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថានកម្ពុជា ប្រចាំត្រីមាសទី១ ឆ្នាំ២០២៥*

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(**ក.ស.វ.**) ធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និង បរិស្ថានកម្ពុជាប្រចាំត្រីមាសទី១ ឆ្នាំ២០២៥ ដោយផ្អែកលើទិន្នន័យទទួលបានពីក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងមតិយោបល់ ជាធាតុចូលពីកិច្ចប្រជុំទូលាយ **ក.ស.វ.** ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងកិច្ចប្រជុំចង្អៀតផ្ទៃក្នុង **ក.ស.វ.** ដោយឈរលើគោលការណ៍បរិយាបន្ននៃសេចក្ដីវិនិច្ឆ័យ រួមមានខ្លឹមសារសង្ខេបដូចខាងក្រោម។

## I. បម្រែបម្រួលគួរឱ្យចាប់អារម្មណ៍

ក្នុងត្រីមាសទី១ ឆ្នាំ២០២៥ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច ដែលបង្ហាញការប្រែប្រួលគំហុកមានដូចខាងក្រោម។ បម្រែបម្រួលនៃសូចនាករមួយចំនួនគួរឱ្យចាប់អារម្មណ៍:

| ល.រ | សូចនាករ | [QoQ] | [YoY] | ទិន្នន័យតារាង... |
|---|---|---|---|---|
| ១ | ថ្លៃបន្លែ | -០,៧% | ១២,៨% | ទី១ |
| ២ | ថ្លៃផ្លែឈើ | -០,១% | ៩,៨% | ទី១ |
| ៣ | ថ្លៃសាច់មាន់ស្រស់ | ១,៥% | ៥,៩% | ទី១ |
| ៤ | ថ្លៃសាច់ត្រី | ០,៧% | ៥,៨% | ទី១ |
| ៥ | ចំណាយថវិកាជាតិសរុប | -១៨,០% | -៣៧,២% | ទី២ |
| ៦ | ការនាំចេញកៅស៊ូ | -៥០,៦% | -៣៧,២% | ទី៥ |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្ដប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរនិងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឱ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀស តាងឱ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

## II. ឧបសម្ព័ន្ធ

## ក. ការពិពណ៌នាទិន្នន័យតារាង

### ១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់ (តារាងទី១)

ក្នុងត្រីមាសទី១ ឆ្នាំ២០២៥ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (មធ្យម) កើនឡើង ០,២% [QoQ] និងកើនឡើង ៤,៨% [YoY]។

តារាង១.១_ បម្រែបម្រួលថ្លៃ [YoY] សម្រាប់ក្រុមទំនិញនិងមុខទំនិញសំខាន់ៗ

| ក្រុមទំនិញ | | មុខទំនិញ | |
|---|---|---|---|
| សម្លៀកបំពាក់និងស្បែកជើង | +៩,១% | បន្លែ | +១២,៨% |
| ម្ហូបអាហារ | +៦,៦% | ផ្លែឈើ | +៩,៨% |
| ការកម្សាន្តនិងវប្បធម៌ | +៤,៥% | សាច់មាន់ | +៥,៩% |
| ការសិក្សា | +៤,៣% | ត្រីស្រស់ | +៥,៨% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | +៣,៩% | សាច់គោ | +៤,៦% |
| ទំនិញនិងសេវាកម្មផ្សេងៗ | +៣,៨% | សាច់ជ្រូក | +៤,៣% |
| ភោជនីយដ្ឋាន | +៣,៥% | អង្ករ | +១,១% |
| គ្រឿងសង្ហារិមនិងសម្ភារៈប្រើប្រាស់ | +៣,១% | | |
| សុខាភិបាល | +១,៧% | | |

តារាង១.២- សន្ទស្សន៍ថ្លៃ និងអតិផរណាតាមត្រីមាសនិងឆ្នាំ (២០២១-២០២៥), ២០០៦=១០០

| ឆ្នាំ | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|
| ២០២១ | សន្ទស្សន៍ | 184.8 | 186.6 | 189.0 | 191.5 | 188.0 |
| | អតិផរណា | 2.1% | 2.8% | 3.2% | 3.5% | 2.9% |
| ២០២២ | សន្ទស្សន៍ | 195.7 | 200.4 | 198.3 | 197.7 | 198.0 |
| | អតិផរណា | 5.9% | 7.4% | 4.9% | 3.2% | 5.3% |
| ២០២៣ | សន្ទស្សន៍ | 199.5 | 201.5 | 203.3 | 203.8 | 202.0 |
| | អតិផរណា | 1.9% | 0.5% | 2.5% | 3.1% | 2.0% |
| ២០២៤ | សន្ទស្សន៍ | 199.0 | 203.0 | 205.3 | 208.1 | 203.9 |
| | អតិផរណា | -0.2% | 0.8% | 1.0% | 2.1% | 0.8% |
| ២០២៥ | សន្ទស្សន៍ | 208.6 | | | | |
| | អតិផរណា | 4.8% | | | | |

តារាង១.៣_ អត្រាប្តូរប្រាក់

| បរិយាយ | ត្រីមាសទី១ ២០២៥ | ត្រីមាសទី១ ២០២៤ |
|---|---|---|
| ៛/ដុល្លារ | ៤ ០០០៛/$ | ៤ ០៤១៛/$ |
| ៛/បាត | ១១៨៛/បាត | ១១១៛/បាត |
| ៛/ដុង | ០,១៥៦៛/ដុង | ០,១៦៣៛/ដុង |
| បាត/ដុល្លារ | ៣៣,៩បាត/$ | ៣៦,៤បាត/$ |

| ដុង/ដុល្លារ | ២៥ ៥៤៨ដុង/$ | ២៤ ៧៨៨ដុង/$ |
|---|---|---|
| យ៉ន់/ដុល្លារ | ៧,៣យ៉ន់/$ | ៧,២យ៉ន់/$ |

## ២. ស្ថានភាពថវិកាជាតិ (តារាងទី២)

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងត្រីមាសទី១ ឆ្នាំ២០២៥ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

តារាង ២.១_ ចំណូលថវិកាជាតិ ឆ្នាំ២០២១ ដល់ ឆ្នាំ២០២៥ (ប៊ីលានរៀល)

| ឆ្នាំ | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|
| ២០២១ | 6095 | 5511 | 4309 | 5287 | 21203 |
| ២០២២ | 6348 | 8047 | 5883 | 6417 | 26695 |
| ២០២៣ | 6766 | 7785 | 5628 | 6609 | 26787 |
| ២០២៤ | 6816 | 6512 | 5961 | 6672 | 25962 |
| ២០២៥ | 8093 | - | - | - | - |

**២.១_ចំណូលថវិកាជាតិ** (តួលេខរតនាគារជាតិ) : អនុវត្តបាន៨ ០៩២,៦ប៊ីលានរៀល ស្មើនឹង ២ ០២៣,២លានដុល្លារអាម៉េរិក ( *មធ្យមប្រចាំខែ ២៨,៤%នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន៧ ៩៣៩,៥ប៊ីលានរៀល ស្មើនឹង ១ ៩៨៤,៩ លានដុល្លារដុល្លារអាម៉េរិក ( *មធ្យមប្រចាំខែ២៨,៥% នៃផែនការ*) និងចំណូលមូលធនចំនួន១៥៣,១ប៊ីលានរៀល ស្មើនឹង ៣៨,៣លានដុល្លារដុល្លារអាម៉េរិក ( *មធ្យមប្រចាំខែ២៥,១% នៃផែនការ*)។ ចំណូលថវិកាជាតិកើនឡើង២១,៣% [QoQ] និងកើនឡើង១៨,៧% [YoY]។

➢ក្នុងចំណូលចរន្ត (តួលេខរតនាគារជាតិ):

- ✓ ចំណូលសារពើពន្ធមានចំនួន ៧ ១២៤,៤ប៊ីលានរៀលកើនឡើ២៤,៤% [QoQ]និងកើនឡើង១៤,៣% [YoY]
- ✓ ចំណូលមិនមែនសារពើពន្ធ មានចំនួន៨១៥,០ប៊ីលានរៀលថយចុះ៤,៦% [QoQ]ប៉ុន្តែកើនឡើង៤១,២% [YoY]។

**តារាង២.១_ មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| ចំណូលសារពើពន្ធ, | %Δ [QoQ] | %Δ [YoY] | ចំណូលមិនមែនសារពើពន្ធ, | %Δ [QoQ] | %Δ [YoY] |
|---|---|---|---|---|---|
| ពន្ធនិងអាករគយ (តួលេខនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករ) | -០,២% | +២២,៦% | អាជ្ញាបណ្ណក្នុងស្រុក | -៧១,៣% | +០,៣% |
| | | | កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | -៥០,៤% | +១០,៥% |
| | | | សម្បទានរ៉ែ | -១៦,៨% | +១៥,៣% |
| ពន្ធដារ (ទួលេខនៃអគ្គនាយកដ្ឋានពន្ធដារ) | +៤៦,៨% | +៨,៥% | អាកាសចរណ៍ស៊ីវិល | -៥៦,៦% | -១១,៩% |
| | | | ផលទុននៃសកម្មភាពទេសចរណ៍ | +២,៣% | +១,១% |

**២.២_ចំណាយថវិកាជាតិ : យោង**តួលេខ រតនាគារជាតិ អនុវត្តបាន៤ ៧៥៨,៤ប៊ីលានរៀល ស្មើនឹង ១ ១៨៩,៦លានដុល្លារអាម៉េរិក ( *មធ្យមប្រចាំខែ១៦,៧%នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ៤ ០៦៨,៣ប៊ីលានរៀល ស្មើនឹង ១ ០១៧,១ លានដុល្លារអាម៉េរិក ( *មធ្យមប្រចាំខែ១៧,០%នៃផែនការ*) និងចំណាយមូលធនចំនួន៦៩០,១ប៊ីលានរៀល ស្មើនឹង ១៧២,៥ លានដុល្លារអាម៉េរិក។ ចំណាយថវិកាជាតិថយចុះ១៨,០% [QoQ] និងថយចុះ៣៧,២% [YoY]។ ក្នុងនោះចំណាយចរន្តថយចុះ១៣,៧% [QoQ] និងថយចុះ៤០,៩% [YoY]។

តារាង ២.២_ ចំណាយថវិកាជាតិ ឆ្នាំ២០២១ ដល់ ឆ្នាំ២០២៥ (ប៊ីលានរៀល)

| ឆ្នាំ | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|
| ២០២១ | 5366 | 4746 | 6333 | 6475 | 22920 |
| ២០២២ | 5889 | 5061 | 5433 | 5722 | 22105 |
| ២០២៣ | 5999 | 6046 | 6601 | 8578 | 27225 |
| ២០២៤ | 7578 | 6111 | 5826 | 5801 | 19515 |
| ២០២៥ | 4758 | - | - | - | - |

**២.៣_ សមតុល្យថវិកាជាតិ** : ថវិកាជាតិនាត្រីមាសទី១នេះ មានអតិរេកចំនួន៣ ៣៣៤,២ប៊ីលានរៀល គិតជាដុល្លារអាម៉េរិកស្មើ៨៣៣,៥លានដុល្លារ (តួលេខរតនាគារជាតិ)។

## ៣_ ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់ (តារាងទី៣)

➡សូចនាកររូបិយវត្ថុផ្សេងៗនាត្រីមាសទី១ ឆ្នាំ២០២៥ មានលក្ខណៈដូចខាងក្រោម (ប៊ីលានរៀល):

| *បរិយាយ* | ត្រីមាស១ ២០២៥ | ត្រីមាស១ ២០២៤ | %Δ |
|---|---|---|---|
| រូបិយវត្ថុ M2 | ២៣៨ ៤៦៨,៣ | ២០០ ៤៣៧,៩ | +១៩,០% |
| រូបិយវត្ថុ M1 | ៥៤ ៦២០,២ | ៤៤ ៦៥១,៣ | +២២,៣% |
| (៖) ក្រៅគ្រឹះស្ថាន | ១៦ ៨៥៦,៨ | ១៦ ០៣១,៣ | +៥,១% |
| ប្រាក់បញ្ញើចរន្ត | ៣៧ ៧៦៣,៥ | ២៨ ៦២០,០ | +៣១,៩% |
| ប្រាក់បញ្ញើផ្សេងទៀត | ១៨៣ ៨៤៨,១ | ១៥៥ ៧៨៦,៦ | +១៨,០% |

➡ ក្រាហ្វខាងក្រោមបង្ហាញសមាមាត្រនៃ ប្រាក់រៀលនៅក្រៅធនាគារ (C) ប្រាក់បញ្ញើចរន្ត (DD) និងប្រាក់បញ្ញើផ្សេងទៀត (**Quasi-Money**)។ [សម្គាល់ : C + DD = M1    M1 + Quasi-Money = M2]។

ក្រាហ្វ៣.១_ សមាសធាតុរូបិយវត្ថុនាចុងគ្រា



➡ សមាមាត្រនៃ ការផ្គត់ផ្គង់ប្រាក់រៀល (ក្នុងនិងក្រៅធនាគារ) និងប្រាក់បញ្ញើជារូបិយបណ្ណ មានដូចតារាងខាងក្រោម។

តារាង៣.១_ សមាមាត្រចំនួនប្រាក់រៀល និងប្រាក់បញ្ញើជារូបិយបណ្ណ ក្នុង $M_2$ ឆ្នាំ២០២៥

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| រូបិយបណ្ណបរទេស (ជាប្រាក់បញ្ញើ) | ៨៥,០% | ៨៥,១% | ៨៥,១% | | | | | | | | | |
| ប្រាក់រៀលសរុប ក្រៅធនាគារ និងបញ្ញើ | ១៥,០% | ១៤,៩% | ១៤,៩% | | | | | | | | | |

ក្រាហ្វ៣.២_បម្រែបម្រួលរូបិយវត្ថុក្នុងត្រីមាសទី១ ឆ្នាំ២០២៥ (ក្នុងវង់ក្រចក = %Δ [YoY])




តារាង៣.៣_ការផ្តល់ឥណទាន (ប៊ីលានរៀល) និងអត្រាការប្រាក់ ប្រចាំត្រីមាស

| បរិយាយ | ត្រីមាសទី១ ២០២៥ | ត្រីមាសទី១ ២០២៤ |
|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ | ២២៧ ២៩៨,២ | ២២០ ០៣៧,៩ |
| ក្នុងនោះ: ជារៀល | ២៦ ៥០៧,៥ | ២៤ ១៨១,៧ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | ២១ ៩៤៨,១ | ២១ ២៣៩,១ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,២% | ៥,៨% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៧% | ៥,៧% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១២,៥% | ១២,១% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ៩,៩% | ៩,៦% |
| អត្រាការប្រាក់កម្ចីជារៀលនៅអិល អូ អិល ស៊ី | ១៦,១% | ១៧,៥% |
| អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | ១៧,១% | ១៧,៤% |

## ៤_ ស្ថានភាពផលិតផលនិងសេវាកម្ម (តារាងទី៤)

➡ ក្នុងត្រីមាសទី១ ឆ្នាំ២០២៥ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

➢ **កសិកម្ម:**

✓ផលិតផលជលផលសម្រេចបាន ២៦១,០៣ន់តោន ថយចុះ៣៤,១% [QoQ] ប៉ុន្តែកើនឡើង២៦,១% [YoY]

✓ផ្ទៃដីដាំកៅស៊ូសរុបមាន ៤២៥,៤ ពាន់ហិកតា ស្ថិតនៅដដែល [QoQ] និងកើនឡើង៤,៥% [YoY]

–ផលិតផលកៅស៊ូមានចំនួន ៦៤,០ ពាន់តោន ថយចុះ៥៦,២% [QoQ] និងថយចុះ៨,៧% [YoY]

–ចំណូលពីការនាំចេញកៅស៊ូ ១១៥,០ លានដុល្លាថយចុះ៥៧,៩% [QoQ] ប៉ុន្តែកើនឡើង១៤,៤% [YoY]

➢រ៉ែ និងថាមពល:

✓អគ្គិសនីសរុបផ្គត់ផ្គង់ដោយ EDC ចំនួន ៤ ៩៤០,៧ GWh កើនឡើង២,២% [QoQ] និងកើនឡើង៦,៦% [YoY] ក្នុងនោះ៖

– វារីអគ្គិសនីចំនួន៩៩៦,៦GWh (២០,២%) ថយចុះ៤៧,៧% [QoQ] និងថយចុះ៧,២% [YoY]

– អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មចំនួន២ ៧៤៨,៤GWh (៥៥,៦% នៃការផ្គត់ផ្គង់ដោយ EDC) កើនឡើង២២,៥% [QoQ] ប៉ុន្តែថយចុះ២,៥% [YoY]។

– អគ្គិសនីផ្គត់ផ្គង់ដោយថាមពលពន្លឺព្រះអាទិត្យមានចំនួន ៤១៩,០ GWh (៨,៥% នៃការផ្គត់ផ្គង់ដោយ EDC) កើនឡើង៤១,៩%[QoQ] និងកើនឡើង៨៦,៧% [YoY]។

– អគ្គិសនីនាំចូលពីប្រទេសជិតខាងមានចំនួន៦០៣,៩GWh (១២,២% នៃការផ្គត់ផ្គង់ដោយ EDC) កើនឡើង ៨៧,៩% [QoQ] និងកើនឡើង៥០,២%[YoY]។

– អគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀត មានចំនួន១៧២,៨GWh (៣,៥% នៃការផ្គត់ផ្គង់ដោយ EDC) មានការកើនឡើង១៤៧,៦% [QoQ] និងកើនឡើង៤៩,៧% [YoY]។

➢ផលិតកម្មស៊ីម៉ងត៍មានចំនួន២ ៧២១,៦ ពាន់តោន កើនឡើង២៨,៩% [QoQ] និងកើនឡើង២៧,១% [YoY]។

➢ឧស្សាហកម្ម:

តារាង៤.១_ ការចុះបញ្ជីរោងចក្រ ឧស្សាហកម្មធុនតូចនិងសិប្បកម្ម នៅ**ក្រសួងឧស្សាហកម្ម** (ចំនួន)

| ប្រភេទ | ត្រីមាសទី១ ២០២៥ | ត្រីមាសទី១ ២០២៤ | %Δ |
|---|---|---|---|
| រោងចក្រថ្មីដែលបានចុះបញ្ជី | ១២០ | ៥៥ | +១១៨,២% |
| ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ២ ៥៣៩ | ២ ១៧៥ | +១៦,៧% |
| ឧស្សាហកម្មធុនតូចនិងសិប្បកម្ម (បើកថ្មី) | ២៦៥ | ២៦០ | +១,៩% |
| ឧស្សាហកម្មធុនតូចនិងសិប្បកម្ម (បន្ត) | ៣៨៦ | ៣៩៤ | -២,០% |

➢**សំណង់** (ការអនុញ្ញាត) មានចំនួន៥ ៣៩៤,៧ពាន់ម² មានការកើនឡើង៣៤,៦%[QoQ] និង កើនឡើង១៧១,៥% [YoY]។ បើគិតជាសាច់ប្រាក់ស្មើនឹង២ ១២៦,៨លានដុល្លារមានការកើនឡើង២០,៤% [QoQ] និងកើនឡើង១៧០,៣% [YoY]។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

តារាង៤.២_ សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ (*ពាន់ម²*)

| បរិយាយ | ត្រីមាសទី១ ២០២៥ | ត្រីមាសទី១ ២០២៤ | %Δ |
|---|---|---|---|
| លំនៅឋាន | ២ ៩៥៧,៤ | ៧៧៧,០ | +២៨០,៦% |
| ឧស្សាហកម្ម | ១ ៨១៧,០ | ៦៦៧,២ | +១៧២,៣% |
| ពាណិជ្ជកម្ម | ៣៨០,០ | ១២៧,៣ | +១៩៨,៦% |
| ទេសចរណ៍ | ៦៤,៩ | ៩៩,៤ | -៣៤,៧% |
| ផ្សេងៗ | ៤០,៥ | ២៧៣,៤ | -៨៥,២% |
| អនុញ្ញាតសរុប | ៥ ៣៩៤,៧ | ១ ៩៨៧,២ | +១៧១,៥% |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាត្រីមាសនេះគឺលំនៅឋាន៥៤,៨% និងឧស្សាហកម្ម៣៣,៧%នៃផ្ទៃក្រឡាសរុប។

➢ **សេវាកម្ម**

តារាង៤.៣_ការចុះបញ្ជីនិងលុបចេញពីបញ្ជីនៅក្រសួងពាណិជ្ជកម្ម ( *ចំនួន*)

| *ប្រភេទ* | *ត្រីមាសទី១ ២០២៥* | *ត្រីមាសទី១ ២០២៤* | %Δ [YoY] |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ១ ៥៦៣ | ១ ៣២៧ | +១៧,៨% |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ២៨៥ | ២៥៨ | +១០,៥% |
| សហគ្រាសដែលបានចុះបញ្ជីពន្ធដារ | ១ ៥៣៥ | ១ ៣០៦ | +១៧,៥% |
| ការស្នើសុំលិខិតអនុញ្ញាតឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក | ២៦ | ១៩ | +៣៦,៨% |
| ក្នុងនោះលិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | ១៥ | ៦ | +១៥០,០% |

➢ **ការងារ**

តារាង៤.៤_ ការស្វែងរកការងារនិងទទួលបានការងារ ( *នាក់*)

| *ប្រភេទ* | *ត្រីមាសទី១ ២០២៥* | *ត្រីមាសទី១ ២០២៤* | %Δ [YoY] |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ( ទីភ្នាក់ងារជាតិមុខរបរនិងការងារ ) | ៦ ៤៤២ | ៨ ១១៤ | -២០,៦% |
| អ្នកទទួលបានការងារធ្វើតាមរយៈ ក្រសួងការងារ និងទីភ្នាក់ងារជ្រើសរើសឯកជន | ១០២ ៤៥៥ | ៨៥ ៧៨៨ | +១៩,៤% |
| អ្នកទទួលបានការងារក្នុងប្រទេស | ៩៣ ៥០៩ | ៧៣ ៨៥៥ | +២៦,៦% |
| អ្នកទទួលបានការងារក្រៅប្រទេស | ៨ ៩៤៦ | ១១ ៩៣៣ | -២៥,០% |

➢ **វិនិយោគ**

តារាង៤.៥_គម្រោងវិនិយោគអនុញ្ញាតដោយក.អ.ក.( ថ្មីនិងពង្រីក )

| *ប្រភេទ* | *ត្រីមាសទី១ ២០២៥* | *ត្រីមាសទី១ ២០២៤* | %Δ [YoY] |
|---|---|---|---|
| អនុញ្ញាតសរុប( លានដុល្លារ ) | ២ ៥០៩,០ | ២ ២០៣,៧ | +១៣,៩% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០ | ៦៦,៦ | - |
| វិស័យឧស្សាហកម្ម ( ក្នុងវង់ក្រចកជាតួលេខរបស់តំបន់សេដ្ឋកិច្ចពិសេស ) | ២ ២៦០,៨ ( ១ ៤៨៩,៦ ) | ៨៦០,៧ ( ៤០១,៨ ) | +១៦២,៧% +២៧០,៧% |
| វិស័យទេសចរណ៍ | ០ | ៥៨៨,៩ | - |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ២៤៨,២ | ៦៨៧,៥ | -៦៣,៩% |
| ចំនួនគម្រោង ថ្មីនិងពង្រីក ( ចំនួន ) | ១៧២ | ១០៦ | +៦២,៣% |
| បង្កើតការងារ ( ពាន់នាក់ ) | ១១៩,៧ | ១០៧,១ | +១១,៨% |

➢ **ទំនិញឆ្លងកាត់កំពង់ផែ**(សរុប២កំពង់ផែ) មានចំនួន៣ ៧៥៥,៦ ពាន់តោន មានការកើនឡើង៧,៩% [QoQ] និងកើនឡើង១៩,៧% [YoY]។ក្នុងនោះ៖

តារាង៤.៦_ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ

| ប្រភេទ | ត្រីមាសទី១ ២០២៥ | ត្រីមាសទី១ ២០២៤ | %Δ [YoY] |
|---|---|---|---|
| ទំនិញឆ្លងកាត់កំពង់ផែស្វយ័តភ្នំពេញ | ១ ០៩៨,៦ | ៩០៨,៦ | +២០,៩% |
| ទំនិញឆ្លងកាត់កំពង់ផែស្វយ័តក្រុងព្រះសីហនុ | ២ ៦៥៧,០ | ២ ២២៨,០ | +១៩,៣% |
| ចំនួនកុងតឺន័រឆ្លងកាត់កំពង់ផែស្វយ័តភ្នំពេញ | ១១១,៥ | ៩២,៥ | +២០,៥% |
| ចំនួនកុងតឺន័រឆ្លងកាត់កំពង់ផែស្វយ័តក្រុងព្រះសីហនុ | ២៧២,១ | ២២២,០ | +២២,៦% |

➢ **ការចុះបញ្ជីនិងចរាចរណ៍**

តារាង៤.៧_ការចុះបញ្ជីម៉ូតូ រថយន្ត និងគ្រោះថ្នាក់ចរាចរណ៍

| ប្រភេទ | ត្រីមាសទី១ ២០២៥ | ត្រីមាសទី១ ២០២៤ | %Δ [YoY] |
|---|---|---|---|
| ចំនួនម៉ូតូបានចុះបញ្ជី(ពាន់គ្រឿង) | ១០៦,៨ | ៨៨,៨ | +២០,២% |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី(ពាន់គ្រឿង) | ១៥,៩ | ១២,៧ | +២៥,២% |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍(លើក) | ៥៥១ | ៧៩៩ | -៣១,០% |

➢ **ប្រៃសណីយ៍និងទូរគមនាគមន៍**

| ប្រភេទ | ត្រីមាសទី១ ២០២៥ | ត្រីមាសទី១ ២០២៤ | %Δ [YoY] |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ៤១,៦ | ៤៤,៧ | -៦,៩% |
| ក្នុងនោះទទួល | ១៤,៥ | ១៥,២ | -៤,៧% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ១០៥,៣ | ១២៤,៥ | -១៥,៤% |
| ក្នុងនោះទទួល | ៥៦,២ | ៦១,១ | -៨,១% |

➢ **ការធ្វើដំណើរតាមផ្លូវអាកាស វប្បធម៌ ទេសចរណ៍ និងបរិស្ថាន**

តារាង៤.៨_អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ ទេសចរណ៍ និងបរិស្ថាន (*ពាន់នាក់*)

| ប្រភេទ | ត្រីមាសទី១ ២០២៥ | ត្រីមាសទី១ ២០២៤ | %Δ [YoY] |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៥០,៣ | ៤៤,០ | +១៤,៣% |
| ភ្ញៀវទេសចរបរទេសទិញបណ្ណទស្សនាអង្គរ | ៣៩៨,៥ | ៣៤៧,៥ | +១៤,៧% |
| ភ្ញៀវទេសចរបរទេសចូលទស្សនារមណីយដ្ឋានព្រះវិហារ | ៥,៥ | ៨,៩ | -៣៨,២% |
| ភ្ញៀវទេសចរបរទេសចូលទស្សនារមណីយដ្ឋានកោះកេរ | ៩,៥ | ៨,១ | +១៨,២% |
| ភ្ញៀវទេសចរបរទេសចូលទស្សនារមណីយដ្ឋានសំបូរព្រៃគុក | ៦,៩ | ៦,២ | +១០,៤% |
| អ្នកដំណើរតាមផ្លូវអាកាស(ក្នុងស្រុក) | ១០០,១ | ៧២,៣ | +៣៨,៤% |
| អ្នកដំណើរតាមផ្លូវអាកាស(អន្តរជាតិ) | ១ ៨៦០,៦ | ១ ៥៦៦,២ | +១៨,៨% |

| | | | |
|---|---|---|---|
| ទំនិញដឹកជញ្ជូនតាមផ្លូវអាកាស | ១៧,១ | ១៥,៦ | +៩,៨% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៤៤១,៨ | ៤១៥,៩ | +៦,២% |
| ចំនួនទេសចរផ្ទៃក្នុង | ៤ ១៦៨,៤ | ៥ ១៤១,២ | -១៨,៩% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ១ ៨៣៨,២ | ១ ៥៨២,៧ | +១៦,១% |
| ✓ តាមផ្លូវអាកាស | ៧៨៩,៤ | ៦៤១,៧ | +២៣,០% |
| ✓ តាមផ្លូវគោកនិងផ្លូវទឹក | ១ ០៤៨,៨ | ៩៤១,០ | +១១,៥% |
| កម្រិតគុណភាពខ្យល់នៅកម្ពុជា (PM2.5) | ២៣,២ | ២៩,៥ | -២១,២% |

## ៥. ស្ថានភាពជញ្ជីងពាណិជ្ជកម្ម (តារាងទី៥)

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាត្រីមាសទី១ ឆ្នាំ២០២៥ មានចំនួន២៨ ០៣០,៣ប៊ីលានរៀល (ស្មើនឹង៧ ០០៧,៦ លានដុល្លារ) ថយចុះ៤,៤% [QoQ] ប៉ុន្តែកើនឡើង១៣,១% [YoY]ក្នុងនោះ៖

តារាង៥.១- ការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | ឯកតា | ត្រីមាសទី១ ២០២៥ | ត្រីមាសទី១ ២០២៤ | %Δ [YoY] |
|---|---|---|---|---|
| ប្រេងសាំង | ពាន់តោន | ២៦៩,១ | ២៩៣,៨ | -៨,៤% |
| ប្រេងម៉ាស៊ូត | ពាន់តោន | ៤៥៦,៧ | ៤៣៤,៥ | +៥,១% |
| ឧស្ម័ន | ពាន់តោន | ១២២,០ | ១១៨,៨ | +២,៧% |
| អគ្គិសនីនាំចូលដោយ EDC | GWh | ៦០៣,៩ | ៤០២,២ | +៥០,២% |
| ដែកសំណង់ | ពាន់តោន | ៣៣០,១ | ១៦៧,៩ | +៩៦,៦% |
| ស៊ីម៉ង់ត៍ | ពាន់តោន | ៥៨,៤ | ៧១,៧ | -១៨,៦% |
| ជីកសិកម្ម | ពាន់តោន | ១៩១,២ | ១៥៥,១ | +២៣,៣% |
| នាំចូលនៃស្ថានទូតមិនធ្វើអាជីវកម្ម | ប៊ីលាន៛ | ៤១,៣ | ២៩,៧ | +៣៩,០% |
| រថយន្តសរុប | ប៊ីលាន៛ | ១ ២៣១,៦ | ៨៣០,៣ | +៤៨,៣% |
| រថយន្តសរុប | គ្រឿង | ១៥ ៥៣៦,០ | ៩ ៥២៧,០ | +៦៣,១% |
| ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | គ្រឿង | ៧ ៥៧០,០ | ៥ ២៩៤,០ | +៤៣,០% |
| ស្រូវសាលី | ពាន់តោន | ៣៨,៨ | ៥៣,១ | -២៧,០% |
| ផ្លែឈើនិងបន្លែ | ពាន់តោន | ៥៣,៤ | ២៣,៧ | +១២៥,៣% |
| នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | ប៊ីលាន៛ | ៧ ៩៨៥,៤ | ៧ ៤៦៦,១ | ៧,០% |

➡ **ការនាំចេញ** ត្រីមាសទី១ ឆ្នាំ២០២៥ មានចំនួន២៤ ២៨៦,១ប៊ីលានរៀល ស្មើនឹង៦ ០៧១,៥លានដុល្លារ (៨៦,៦% នៃការនាំចូល) កើនឡើង២,៩% [QoQ] និងកើនឡើង១៩,៦%[YoY]។

តារាង៥.២_បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | *ឯកតា* | *ត្រីមាសទី១ ២០២៥* | *ត្រីមាសទី១ ២០២៤* | *%Δ* [YoY] |
|---|---|---|---|---|
| វាយនភណ្ឌនិងស្បែកជើង | ប៊ីលាន ៛ | ១៤ ០៣១,៥ | ១១ ៨៥៥,៧ | +១៨,៤% |
| អង្ករ | ពាន់តោន | ២០៨,១ | ១៧៨,២ | +១៦,៨% |
| ផលិតផលនេសាទ | តោន | ៩៨,៦ | ៩៥,៣ | +៣,៤% |
| កៅស៊ូ | ពាន់តោន | ៤២,២ | ៦៧,១ | -៣៧,២% |
| ខ្សាច់ | ពាន់តោន | ១២ ១០៨,២ | ៧ ៩៦៦,០ | +៥២,០% |

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**

**ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

**ឆែម គាតរិទ្ធី**




ក្រុមបច្ចេកទេសរៀបចំសេចក្តីព្រាងរបាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន

អាសយដ្ឋាន: អគារមិត្តភាព លេខ៨១ មហាវិថីសហព័ន្ធរុស្ស៊ី ខណ្ឌ៧មករា រាជធានីភ្នំពេញ

ទូរស័ព្ទ: ០៨៥ ៧៧៧ ៩៨០ / ០១២ ៦៦២ ៣១៦ ទូរសារ: ០២៣ ២២១ ៨៩០

Email: chyanit168@gmail.com / mamsarith@yahoo.com